# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៤ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការជួយសង្គ្រោះក្មេងរងគ្រោះដោយគ្រឿងញៀន

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-យោងតាមតម្រូវការចាំបាច់

## សម្រេច

**ប្រការ ១ .-**

ត្រូវបានបង្កើតគណៈកម្មការជួយសង្គ្រោះក្មេងរងគ្រោះដោយគ្រឿងញៀន ដែលមានសមាសភាព ដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | ស៊ូ ភិរិន្ទ | អភិបាលខេត្តសៀមរាប | ប្រធាន |
| ២-ឯកឧត្តមឧត្តមសេនីយ៍ឯក | នេត សាវឿន | អគ្គស្នងការរងនគរបាលជាតិកម្ពុជា | អនុប្រធាន |
| ៣-ឯកឧត្តមឧត្តមសេនីយ៍ឯក | ជុំ ហាក់ | មេបញ្ជាការរងកងទ័ពជើងគោក | អនុប្រធាន |

| | | | |
|---|---|---|---|
| ៤-ឯកឧត្តមឧត្តមសេនីយ៍ឯក | លួ រ៉ាមីន | អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន | អនុប្រធាន |
| ៥- ឯកឧត្តមឧត្តមសេនីយ៍ទោ | ខឹម ពិសេន | មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស | អនុប្រធាន |
| ៦-ឯកឧត្តម | ទេព លន់ | អគ្គនាយកបច្ចេកទេសនៃក្រសួងសុខាភិបាល | សមាជិក |
| ៧-ឯកឧត្តម | គង់ នាគ | អគ្គនាយកបច្ចេកទេសនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៨-ឯកឧត្តម | ឡៅ ហ៊ុច | អគ្គនាយកអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៩-ឯកឧត្តម | គុំ សារ៉ុន | អគ្គនាយកនៃក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ | សមាជិក |

## ប្រការ ២ .-

គណៈកម្មការជួយសង្គ្រោះក្មេងរងគ្រោះដោយគ្រឿងញៀន មានមុខងារ និងភារកិច្ចដូចតទៅ :

-ប្រមូលក្មេងប្រើប្រាស់ និងញៀនគ្រឿងញៀនមកអប់រំ និងស្តារនីតិសម្បទានៅក្នុងមណ្ឌលអប់រំ

-បង្កើតកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងជំនាញដល់ក្មេងរងគ្រោះដោយគ្រឿងញៀន

-ធ្វើរបាយការណ៍អំពីលទ្ធផលការងារ តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី ជូនប្រមុខរាជរដ្ឋាភិបាល ។

## ប្រការ ៣ .-

គណៈកម្មការនេះ មានសិទ្ធិបង្កើតក្រុមការងារមួយជាជំនួយការ ។

## ប្រការ ៤ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន អភិបាលខេត្ត ក្រុងពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចប្រការ ៤

-រាជកិច្ច

-ឯកសារ កាលប្បវត្តិ

Decision 13 07 06 doc